# វេទិការៀនសូត្រស្តីពីប្រព័ន្ធបច្ចេកវិទ្យា និងទំនាក់ទំនងលើកទី៣៩

## ក្រោមប្រធានបទ បញ្ញាសិប្បនិម្មិតក្នុងការងារ និងការការពារទិន្នន័យ

*ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០២៥*

*ម៉ោង ៨:០០ ដល់ ១២:០០ ថ្ងៃត្រង់*

*តាមរយៈការចូលរួមផ្ទាល់ និងតាមប្រព័ន្ធអនឡាញ Zoom Meeting*

ទីតាំងភោជនីយដ្ឋានទន្លេបាសាក់២

អ្នកចូលរួមសរុប ៨៨នាក់(ស្រ្តី៣៨នាក់)



## ១. សេចក្តីផ្តើម

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) ជាអង្គការសមាជិកភាពដ៏ធំ និងមានវ័យចំណាស់ជាងគេមួយនៅក្នុងប្រទេសកម្ពុជា។  ក្នុងឆ្នាំ២០២៥ អង្គការ គ.ស.ក មានសមាជិកជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសចំនួនជិត២០០ស្ថាប័ន។ បច្ចុប្បន្ននេះ អង្គការ គ.ស.ក បានកំពុងអនុវត្តកម្មវិធីមជ្ឈមណ្ឌលអភិបាលកិច្ចដំណាក់កាលទី៥ ពីឆ្នាំ២០២៤ ដល់ ២០២៨។ កម្មវិធីនេះ មានគោលបំណងសំខាន់គឺពង្រឹងអង្គការសង្គមស៊ីវិល តាមរយៈការធ្វើអោយប្រសើរឡើង នូវបរិយាកាសអំណោយផល និងលំហប្រជាធិបតេយ្យ។



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152

#9-11, Street. 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

អង្គការគ.ស.ក ត្រៀមនឹងរៀបចំវេទិកាវៀនសូត្រស្តីពីបញ្ញាសិប្បនិម្មិតក្នុងការងារ និងការការពារទិន្នន័យ ទៅកាន់អង្គការសមាជិកដើម្បីបង្កើនចំណេះដឹងលើការប្រើប្រាស់បញ្ញាសិប្បនិម្មិតក្នុងការសម្រួលដល់ការងារ ការសិក្សាស្វែងយល់បន្ថែមអោយកាន់តែស៊ីជម្រៅលើការបង្កើត និងអត្ថប្រយោជន៍នៃសេវាចុះឈ្មោះដែនជាតិ Domain Name.kh និងបង្កើនការយល់ដឹងបន្ថែមពីការការពារទិន្នន័យតាមប្រព័ន្ធអនឡាញនានា។ វេទិកានេះនឹងសម្របសម្រួលដោយអ្នកបច្ចេកទេសពីស្ថាប័នរដ្ឋ ក្រុមហ៊ុនឯកជន ព្រមទាំងក្រុមការងារស្ម័គ្រចិត្តផ្នែកទំនាក់ទំនង និងបច្ចេកវិទ្យាគមនាគមន៍នៃអង្គការគ.ស.ក និងអង្គការដៃគូ។ វេទិកានេះនឹងរៀបចំឡើងនាថ្ងៃទី**២២ ខែឧសភា ឆ្នាំ២០២៥ នៅភោជនីយដ្ឋានទន្លេបាសាក់២។**

## ២. គោលបំណងនៃវេទិកាវៀនសូត្រ

1. ស្វែងយល់ពី របៀបបង្កើត និងអត្ថប្រយោជន៍នៃសេវាចុះឈ្មោះដែនជាតិ
2. ស្វែងយល់បន្ថែមលើប្រព័ន្ធឌីជីថលនៃការប្រើប្រាស់បញ្ញាសិប្បនិម្មិតដើម្បីសម្រួលការងារ
3. យល់ដឹងបន្ថែមពីការការពារទិន្នន័យ
4. ពង្រីកទំនាក់ទំនងក្នុងចំណោមអ្នកកាន់តួនាទីផ្នែកទំនាក់ទំនង និងបច្ចេកវិទ្យាគមនាគមន៍។

## ៣. ការធ្វើបទបង្ហាញ

ការធ្វើបទបង្ហាញដោយ**លោក ប៊ុន ភូមេន្ទ្រ** មន្ត្រីជំនាញពីខាងនិយ័តករ និងទូរគមនាគមន៍៖

Kh: គឺបញ្ជាក់ពីអត្តសញ្ញាណរបស់ជាតិយើង។

***បើប្រើ .com.kh ផ្តល់ជូនទៅតែអង្គការ និងសហគមន៍ដែលបានចុះបញ្ជីប៉ុណ្ណោះ។

**អ្វីជាឈ្មោះដែន (Domain Name .kh)

- ឈ្មោះដែនគឺជាឈ្មោះកំណត់អត្តសញ្ញាណតែមួយគត់នៅក្នុងសកលលោក ដែលសម្រួលឱ្យសាធារណជនអាចទៅរកធនធានប្រព័ន្ធអ៊ីនធឺណិត។

  ឧទាហរណ៍៖ mptc.gov.kh; trc.gov.kh; facebook.com; google.com
- ឈ្មោះដែនជាតិ សំដៅដល់ឈ្មោះដែនដែលមានពាក្យខ្មែរ (ដត់ខ្មែរ) និង.kh(ដត់ ខេអេច) នៅខាងចុង។ ឋានានុក្រមនៃឈ្មោះដែនជាតិត្រូវបែងចែក ជាដែនកម្រិតទី១ ដែនកម្រិតទី២ និងដែនកម្រិតផ្សេងទៀត។
- ដែនកម្រិតទី១ ឬដែនកម្រិតខ្ពស់ (top level domain) ជាអ្វី?

ដែនកម្រិតទី១ ឬដែនកម្រិតខ្ពស់) (top level domain) សំដៅដល់ដែនកម្រិតខ្ពស់បំផុតនៅក្នុងឋានានុក្រមនៃឈ្មោះដែន។ ឧទាហរណ៍៖ .kh; .th; .jp; .kr; .com; net;..

- តើដែនកម្រិតទី១ទូទៅ (generic top level domain - gTLD) និងដែនកម្រិតទី១តាមកូដប្រទេស (country code top-level domain - ccTLD) ខុសគ្នាដូចម្តេច?
  - ដែនកម្រិតទី១ទូទៅគឺជាដែនកម្រិតខ្ពស់បំផុតនៅក្នុងឋានានុក្រមនៃឈ្មោះដែនក្នុងប្រព័ន្ធអ៊ីនធឺណិត ដែលមានឈ្មោះដូចជា .com, .net និង .org។ ដែនកម្រិតទី១ទូទៅមិនត្រូវបានកំណត់ឬ

តំណាងឱ្យប្រទេសណាមួយទេហើយដែននេះត្រូវបានគ្រប់គ្រងដោយសាជីវកម្មគ្រប់គ្រងអាសយដ្ឋានឈ្មោះនិងលេខអ៊ីនធឺណិត (Internet Corporation for Assigned Names and Numbers - ICANN).

- ដែនកម្រិតទី១ តាមកូដប្រទេស (country code top-level domain - ccTLD) គឺជាដែនកម្រិតខ្ពស់បំផុតនៅក្នុងឋានានុក្រមនៃឈ្មោះដែនក្នុងប្រព័ន្ធអ៊ីនធឺណិតដែលត្រូវបានរក្សាទុកសម្រាប់ប្រទេស តំបន់ ឬទីតាំងភូមិសាស្ត្រណាមួយ។ ឧទាហរណ៍៖ .kh ជាដែនកម្រិតទី១តាមកូដប្រទេសសម្រាប់ព្រះរាជាណាចក្រកម្ពុជា។
- ឧទាហរណ៍ sky.khនិង sky.org

**សេវាសម្រាប់ឈ្មោះដែនប្រភេទ .org.kh**

| | **ឆ្នាំទី១** | **ឆ្នាំបន្ទាប់** |
|---|---|---|
| ចំនួន ១ តួ (ឧ: a.org.kh) | ១២ លានរៀល | ៣២ ម៉ឺនរៀល |
| ចំនួន ២ តួ (ឧ: ab.org.kh) | ៦ លានរៀល | ៣២ ម៉ឺនរៀល |
| ចំនួន ៣ តួ (ឧ: abc.org.kh) | ៣ លានរៀល | ៣២ ម៉ឺនរៀល |
| ចាប់ពី ៤ តួ (ឧ: abcd.org.kh) | ១២ ម៉ឺនរៀល | ១២ ម៉ឺនរៀល |

**អត្ថប្រយោជន៍ នៃការប្រើប្រាស់ឈ្មោះដែនជាតិ**

- ❑ បង្កើនភាពទុកចិត្ត និងការជឿជាក់
- ❑ បង្កើនភាពងាយស្រួលក្នុងការស្វែងរក (SEO)
- ❑ ទទួលបានការការពារ

****សម្រាប់លក្ខខណ្ឌស្នើសុំចុះឈ្មោះដែនជាតិ៖**

- ត្រូវមានលិខិតអនុញ្ញាតបង្កើតអង្គការឬសមាគមដែលចេញដោយក្រសួងមហាផ្ទៃឬក្រសួងការបរទេស
- ច្បាប់ចម្លងនៃអត្តសញ្ញាណប័ណ្ណរបស់នាយកអង្គការឬសមាគម
- ត្រូវមាន Name.server សិនមុនប្រើ Domain.name.kh

** នៅក្នុងការប្រើប្រាស់ Domain.name.kh ខាងនិយ័តករ មិនមានជាកំហិតក្នុងការតម្រូវអោយអង្គការ និងសមាគមត្រូវតែប្រើនោះទេ តែនៅពេលដែលអង្គការប្រើ org.kh គឺសុទ្ធតែជាអង្គការដែលបានចុះបញ្ជីជាមួយក្រសួងត្រឹមត្រូវ។

- តើក្នុង១ Domain អាចប្រើបានប៉ុន្មានអ៊ីម៉ែល?=> វាអាស្រ័យលើកញ្ចប់សេវានោះ គឺអាស្រ័យលើក្រុមហ៊ុនឬសេវាទី៣ ដែលធ្វើលើសេវានេះ ព្រោះខាងនិយ័តករទូរគមនាគមន៍មានតួនាទីតែលើការបង្កើតឈ្មោះជូនតែប៉ុណ្ណោះ។


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
#9-11, Street. 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

- លេខទំនាក់ទំនងHotline របស់និយ័តករទូរគមនាគមន៍ ៦៧៨៩។

ការធ្វើបទបង្ហាញដោយ**លោក ចាន់ ណាត** ក្រុមការងារបច្ចេកទេសផ្នែកទំនាក់ទំនងព័ត៌មាន និងបច្ចេកវិទ្យា នៃអង្គការ គសក ស្តីអំពីអត្ថប្រយោជន៍នៃការប្រើប្រាស់បញ្ញាសិប្បនិម្មិតក្នុងការងារៈ

បច្ចេកវិទ្យា AI កំពុងផ្លាស់ប្តូររបៀបដំណើរការរបស់អាជីវកម្ម ដោយនាំមកនូវប្រសិទ្ធភាពនិងសមត្ថភាពក្នុងការបង្កើតទិន្នន័យដោយផ្អែកលើAI សម្រាប់ក្រុមហ៊ុនដែលមានការយល់ដឹងពីរបៀបប្រើប្រាស់ AI មិនមែនជាគុណសម្បត្តិទេ ប៉ុន្តែជាការចាំបាច់។

- **តើអ្វីទៅជា Meet Cody AI ជាអ្វី?**

Meet Cody AI គឺជាជំនួយការសម្រាប់អាជីវកម្ម ដែលបានបង្កើតឡើងដើម្បីសម្រួលភារកិច្ច ដោយប្រើប្រាស់មូលដ្ឋានចំណេះដឹងផ្ទាល់ខ្លួននិងជំនួយដល់ការធ្វើការងារ។
ឧបករណ៍ AI នេះជួយបង្កើនផលិតភាពក្រុម ដោយៈ

- ជួយផ្តល់ចម្លើយបានយ៉ាងរហ័ស
- ជួយក្នុងការធ្វើការងារ
- គាំទ្រដល់ការផ្តល់សេវាអតិថិជន

- **អត្ថប្រយោជន៍របស់ Meet Cody AI**

- បង្កើនផលិតភាពផ្តល់ចម្លើយភ្លាមៗ, ជួយបង្កើតខ្លឹមសារ, និងជួយសម្រួលដល់ការងារដែលធ្វើញឹកញាប់។
- ជួយសម្រេចចិត្តបានល្អយកព័ត៌មានពីទិន្នន័យក្រុមហ៊ុនបានរហ័ស ដើម្បីជួយសម្រេចចិត្តដោយផ្អែកលើព័ត៌មានថ្មីៗនិងទំនុកចិត្ត។
- សម្រួលការបណ្តុះបណ្តាលប្តូរចម្លើយតាមតួនាទី ជួយ HR បណ្តុះបណ្តាលបានល្អ និងសន្សំពេលវេលា។
- បង្កើនសេវាអតិថិជនដោះស្រាយសំណួររបស់អតិថិជន និងជួយដោះស្រាយបញ្ហាបានលឿន។
- ការពារទិន្នន័យប្រើការអ៊ិនគ្រីប និងគោរពតាមស្តង់ដារ SOC II ដើម្បីរក្សាឯកជនភាព។

- **គន្លឹះខ្ពស់ៗសម្រាប់ប្រើ Cody AI ឲ្យមានប្រសិទ្ធភាពខ្ពស់**

- ភ្ជាប់ជាមួយឧបករណ៍សំខាន់ៗរួមបញ្ចូល Cody ជាមួយ Slack ឬ CRM ដើម្បីសម្រួលលំហូរការងារ។
- បង្កើត Bot ជាក់លាក់បង្កើត Bot សម្រាប់ផ្នែកជាក់លាក់ ដូចជា HR ឬ Marketing។
- ប្រើ Editor ខាងក្នុងកែសម្រួលព័ត៌មានឲ្យត្រឹមត្រូវ ដើម្បីបង្កើនភាពត្រឹមត្រូវនៃចម្លើយ។
- ប្រើ Data Insights ពិនិត្យព័ត៌មានវិភាគជាប្រចាំ ដើម្បីកែលម្អយុទ្ធសាស្រ្ត។
- បើកការបង្ហាញប្រភពកំណត់ឲ្យ Meet Cody បង្ហាញប្រភពនៃចម្លើយ ដើម្បីបង្កើនភាពជឿជាក់។

ការធ្វើបទបង្ហាញដោយ**លោក ស៊ីន វិជ្ជារ៉ា** ជាមន្រ្តីផ្នែកអភិវឌ្ឍន៍គេហទំព័រ និងព័ត៌មានវិទ្យា របស់អង្គការទិន្នន័យដើម្បីការអភិវឌ្ឍ (ODC) ស្តីអំពីសុវត្ថិភាព និងការពារទិន្នន័យ។

**ហេតុអ្វីបានជាការពារទិន្នន័យមានសារៈសំខាន់?**

- ការកំណត់ប្រព័ន្ធការពារទិន្នន័យដើម្បីការពារប្រឆាំងនឹងការលួច
- ទិន្នន័យដែលមិនបានការពារ អាចបង្កើតឱ្យមានបញ្ហាធ្ងន់ធ្ងរដល់អាជីវកម្ម
- លទ្ធផលអាចមានដូចជាៈ ការបាត់បង់ទំនុកចិត្តពីភាគីទីប

### អ្វីហៅជាការពារទិន្នន័យ?

- ដើម្បីធានាថាទិន្នន័យមានសុវត្ថិភាពនិងអាចចូលរួមប្រើបានតែដោយបុគ្គលដែលមានសិទ្ធិ
- រួមមានការបំលែងកូដនីយកម្មសម្រាប់ទិន្នន័យការគ្រប់គ្រងការចូលប្រើនិងការផ្ទុកក្នុងប្រព័ន្ធសុវត្ថិភាព

### ប្រភេទទិន្នន័យផ្ទាល់ខ្លួន

- ឈ្មោះ  អាស័យដ្ឋាន លេខទូរស័ព្ទ អ៊ីម៉ែល
- ទិន្នន័យរសើបព័ត៌មានសុខភាព ហិរញ្ញវត្ថុ ចំណង់ចំណូលចិត្ត

### គ្រោះថ្នាក់ដល់ទិន្នន័យ

**ហានិភ័យ និងការប្រឈមទូទៅ៖**

- ការវាយប្រហារបច្ចេកវិទ្យា
- គ្រោះថ្នាក់ពីខាងក្នុង (ការធ្វើអោយខូចខាតដោយចេតនា ឬដោយអចេតនា
- ការគ្រប់គ្រងការចូលដំណើរការខ្សោយ និងពាក្យសម្ងាត់ខ្សោយ
- ការខ្វះកូដនីយកម្ម និងវិធានការសុវត្ថិភាព

### គោលការណ៍នៃការពារទិន្នន័យ

**គោលការណ៍សំខាន់៖**

- ការបង្រួមទិន្នន័យ ប្រមូលតែអ្វីដែលចាំបាច់
- ការច្បាស់លាស់ ជម្រាបអោយអ្នកប្រើប្រាស់ដឹងអំពីការប្រមូល និងការប្រើប្រាស់ទិន្នន័យ
- សុវត្ថិភាព ធ្វើអោយមានវិធានការការពារដ៏រឹងមាំ
- ការទទួលខុសត្រូវ ការត្រួតពិនិត្យ និងសវនកម្មទៀងទាត់

### របៀបធ្វើអោយទិន្នន័យមានសុវិត្ថភាព

**សម្រាប់ស្ថាប័ន៖**

- រៀបចំការវាយតម្លៃហានិភ័យ
- បណ្ដុះបណ្ដាលបុគ្គលិកអំពីការពារទិន្នន័យ និងឯកភាព
- ប្រើប្រាស់ការផ្ទៀងផ្ទាត់អត្តសញ្ញាណ និងកូដនីយកម្មដ៏រឹងមាំ
- ដំណើរការទិន្នន័យ និងគោលនយោបាយការលុបចោលទិន្នន័យមិនចាំបាច់
- អនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ

***** សម្រាប់បុគ្គល៖**

- ប្រើពាក្យសម្ងាត់ខ្លាំង និងមានភាពប្លែក
- បើកប្រព័ន្ធផ្ទៀងផ្ទាត់ពីរកត្តា
- ប្រយ័ត្នចំពោះអ៊ីម៉ែលក្លែងបន្លំ និងការបោកប្រាស់តាមប្រព័ន្ធផ្សេងៗ
- ពិនិត្យការកំណត់ឯកជនភាពលើកម្មវិធី និងឧបករណ៍ជានិច្ច

**៥. របៀបវារៈ**

| ម៉ោង | មាតិកា | អ្នកសម្របសម្រួល |
|---|---|---|
| ០៨:០០ -០៨:៣០ | ការចុះឈ្មោះអ្នកចូលរួម | ក្រុមការងារ គ.ស.ក |
| ០៨:៣០-០៨:៤០ | - ការណែនាំពី បទបញ្ហាផ្ទៃក្នុងសម្រាប់វេទិកាវៀនសូត្រ<br>- គោរពភ្លេងជាតិ<br>- ប្រកាសគោលបំណងវេទិកាវៀនសូត្រ | **អ្នករៀបចំកម្មវិធី**<br>អង្គការ គ.ស.ក |
| ០៨:៤០-៨:៥០ | កិច្ចស្វាគមន៍ និងបើកកម្មវិធីដោយតំណាងអង្គការ គ.ស.ក | អង្គការ គ.ស.ក |
| ៨:៥០ -១០:០០ | **<u>បទបង្ហាញស្ដីពី៖</u>** របៀបបង្កើត និងអត្ថប្រយោជន៍នៃសេវាចុះឈ្មោះដែនជាតិ Domain Name.kh<br>• <u>តើអ្វីជាដែនជាតិ?</u><br>• <u>តើការបង្កើតដែនជាតិតម្រូវការឯកសារអ្វីខ្លះ?</u><br>• <u>តើការប្រើប្រាស់ដែនជាតិមានសារៈប្រយោជន៍អ្វីខ្លះដល់អង្គការសង្គមស៊ីវិល?</u><br>***(សំណួរនិងចម្លើយ)*** | **តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** |
| ១០:០០ -១០:១៥ | **ការថតរូបជុំគ្នា និងសម្រាកពិសារអាហារសម្រន់** | |
| ១០:១៥ -១២:០០ | **<u>ការធ្វើបទបង្ហាញពី៖</u>** អត្ថប្រយោជន៍ នៃការប្រើប្រាស់បញ្ញាសិប្បនិម្មិតក្នុងការងារ<br>***(សំណួរនិងចម្លើយ)*** | **លោក ចាន់ ណាត**<br>ក្រុមការងារបច្ចេកទេសផ្នែកទំនាក់ទំនងព័ត៌មាន និងបច្ចេកវិទ្យា នៃអង្គការ គ.ស.ក |
| ១២:០០-១:៣០ | **ពិសារអាហារថ្ងៃត្រង់រួមគ្នា** | |
| ១:៣០-១:៤៥ | **ការវាយតម្លៃវេទិការៀនសូត្រ** | |
| ១:៤៥-៣:០០ | **<u>ការធ្វើបទបង្ហាញពី៖</u>** ការការពារទិន្នន័យ (Social in Engineering Attack) | តំណាងអង្គការទិន្នន័យអំពីការអភិវឌ្ឍ (ODC) |
| ៣:០០-៣:១៥ | **សម្រាកពិសារអាហារសម្រន់** | |



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152

#9-11, Street. 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

| | | |
|---|---|---|
| ៣:១៥-៤:៣០ | **<u>បន្តការធ្វើបទបង្ហាញពី៖</u>** ការការពារទិន្នន័យ (Social in Engineering Attack) | តំណាងអង្គការទិន្នន័យអំពីការអភិវឌ្ឍ (ODC) |
| ៤:៣០-៤:៤៥ | **<u>បិទកម្មវិធី</u>** | |

***<u>កំណត់សម្គាល់:</u>*** *អង្គការ គ.ស.ក សូមរក្សាសិទ្ធិផ្លាស់ប្តូរ ឬ កែប្រែរបៀបវារៈនៃកម្មវិធីក្នុងករណីចាំបាច់។ អង្គការ គ.ស.ក នឹងយករូបថតនៃវេទិការៀនសូត្រនេះសម្រាប់ការប្រើប្រាស់ផ្លូវការផ្សេងៗ។ សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់* *raingsey.roeung@ccc-cambodia.org*